គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable development for Cambodia

# ឯកសារទស្សនាទាន
# មហាសន្និបាតប្រចាំឆ្នាំ
# ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥

មជ្ឈមណ្ឌល **ដាយកូនៀរ** រាជធានីភ្នំពេញ ប្រទេសកម្ពុជា

## <u>សាវតារះ</u>

អនុលោមតាមលក្ខន្តិកៈរបស់ខ្លួន គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បើកមហាសន្និបាតប្រចាំឆ្នាំ ***(AGM)*** ជាមួយសមាជិក និងដៃគូរបស់ខ្លួន ដើម្បីពិនិត្យឡើងវិញទៅលើលទ្ធផលការងារដែលសម្រេចបាននៅក្នុងឆ្នាំចាស់ និងពិភាក្សាផែនការសម្រាប់ឆ្នាំបន្ទាប់។ មហាសន្និបាតប្រចាំឆ្នាំ បានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១មកហើយជារៀងរាល់ឆ្នាំ មហាសន្និបាតនេះក៏ពិភាក្សាផងដែរនូវបញ្ហាសំខាន់ៗជាច្រើន ដូចជានិន្នាការនៃការអភិវឌ្ឍ បរិយាកាសអំណោយផល យេនឌ័រ បរិយាប័ន្នសង្គម គុណភាពសេវាកម្ម (អប់រំ និងសុខភាព) អភិបាលកិច្ច និងបញ្ហាជាច្រើនទៀត។ ឆ្នាំទៅមិញ មហាសន្និបាតប្រចាំ២០១៥ ត្រូវបានធ្វើឡើងក្រោមប្រធានបទ "**ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា**"។

នៅឆ្នាំ២០១៦នេះ ដោយទទួលបានមតិត្រឡប់ពីសមាជិក និងគណៈកម្មាធិការប្រតិបត្តិ ***(EXCOM)*** របស់ គ.ស.ក មហាសន្និបាតនឹងប្រព្រឹត្តទៅក្រោមប្រធានបទ៖ "**ការចូលរួមរបស់អង្គការគ.ស.ក និងសមាជិក នៅក្នុងកិច្ចអភិវឌ្ឍប្រទេសកម្ពុជា បន្ទាប់ពីច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអនុមត័ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព *(SDGs)***"។ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាក្នុងខែសីហា ឆ្នាំ២០១៥ហើយរហូតដល់ឥឡូវ នៅតែមិនទាន់ច្បាស់ពីមធ្យោបាយនៃការអនុវត្តច្បាប់នេះនៅឡើយ ពីព្រោះសេចក្តីណែនាំនៃការអនុវត្តច្បាប់នេះនៅមិនទាន់រៀបចំរួច។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ***(SDGs)*** ត្រូវបានអនុម័តដោយប្រមុខរដ្ឋនៃប្រទេសនានាជាសមាជិកអង្គការសហប្រជាជាតិ ក្នុងអំឡុងមហាសន្និបាតលើកទី៧០របស់អង្គការសហប្រជាជាតិមហាសន្និបាតអ.ស.ប នៅក្នុងទីក្រុងញូវយ៉ក។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ***(SDGs)*** គឺជារបៀបវារៈគ្រប់ជ្រុងជ្រោយមួយ ដែលបំពេញឲ្យរបៀបវារៈដែលមិនទាន់សម្រេចបានរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ***(MDGs)*** ហើយពិនិត្យឡើងវិញទៅលើការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយផ្អែកលើទស្សនៈរួមបញ្ចូលគ្នា និងមានតុល្យភាពនៃជ្រុងទាំងបី គឺ សង្គម សេដ្ឋកិច្ច និងបរិស្ថាន។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ***(SDGs)*** មាន ១៧គោលដៅ ១៦៩ទិសដៅ និងប្រហែលជាង ២០០សូចនាករ (ដែលត្រូវកែសម្រួលដាក់ឲ្យអនុវត្តនៅជំណាច់ខែមីនា ឆ្នាំ២០១៦)។ របៀបវារៈនេះតម្រូវឲអង្គការសង្គមស៊ីវិល ជាពិសេស គ.ស.ក និងសមាជិកត្រូវពង្រឹងកម្មវិធី ស្ថាបន័ និងវិធីសាស្រ្តដោះស្រាយការងាររបស់គេឲមានប្រាស័យទាក់ទងគ្នា និងប្រកបដោយប្រសិទ្ធិភាព។

នៅឆ្នាំនេះ មហាសន្និបាតរបស់ គ.ស.ក នឹងប្រារព្ធធ្វើនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ជាមួយនឹងកម្មវិធី វាគ្មិន ការចូលរួមពីភ្ញៀវកិត្តិយស ការដាក់បង្ហាញឯកសារ និងការតាំងពិព័រណ៍ដែលគួរឲ្យចាប់អារម្មណ៍។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
25/08/2015 GPP 24/08/2018
Symbol of Trust

**គោលបំណងៈ**

១. ជម្រាបជូនពីសមិទ្ធិផលសំខាន់ៗដែលសម្រេចបាន របស់ គ.ស.ក និងអង្គការសមាជិក នៅក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជានៅក្នុងឆ្នាំ២០១៥
២. ប្រមូលនូវការពិភាក្សា និងការគាំទ្រជាអាទិភាពសម្រាប់ គ.ស.ក យកមកអនុវត្តនារយៈពេលប្រាំឆ្នាំបន្តទៀត ចាប់ពីឆ្នាំ ២០១៦ ដល់ ២០២០
៣. ចែករំលែក និងពិភាក្សារួមគ្នាលើបញ្ហាព្រួយបារម្ភណ៍ កិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការតស៊ូមតិ និងកិច្ចខិតខំប្រឹងប្រែងក្នុងការឆ្លើយតបទៅនឹងរបចថ្មីជាពិសេសបរិបទនៃច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលបន្ទាប់ពីបានអនុម័តរួច និង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
៤. ពិភាក្សាដេញដោលនៃពហុភាពជាដៃគូក្នុងការរៀបចំធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ***(SDGs)*** ក្នុងប្រទេសកម្ពុជា។

**របៀបវារៈ**

| ម៉ោង | ប្រធានបទ | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៧:៣០–៨:១៥ | ទំនាក់ទំនង និងចុះឈ្មោះ | |
| ៨:១៥–៨:៣០ | ការណែនាំ និងគោរពភ្លេងជាតិ | **លោកឃន ម៉ិនថុង**<br>ប្រធានផ្នែកប្រតិបត្តិការ គ.ស.ក |
| ៨:៣០-៨:៥០ | របាំជូនពរ | អង្គការគ្រួសារយើង (សមាជិក គ.ស.ក) |
| ៨:៥០– ៩:០០ | **សុន្ទរកថាស្វាគមន៍** | **លោក នាត់ សុភាព**<br>ប្រធានគណៈកម្មាធិការប្រតិបត្តិ គ.ស.ក |
| ៩:០០–៩:១០ | **សុន្ទរកថាបើក** | **ឯកឧត្តម សក់ សេដ្ឋា**<br>រដ្ឋលេខាធិការ **ក្រសួងមហាផ្ទៃ** និងជាប្រធានលេខាធិការដ្ឋាន **គ.ជ.អ.ប** |
| ៩:១០ – ៩:៣០ | **ការប្រកាសជាផ្លូវការៈ**<br>• *ការប្រកាសជាផ្លូវការនូវគណៈកម្មាធិការប្រតិបត្តិសម្រាប់ឆ្នាំ ២០១៦*<br>• *ចំណាប់អារម្មណ៍របស់ អ្នកស្រី **សុខ បញ្ញា** តំណាងគណៈកម្មាធិការ២០១៥*<br>• *ការប្រកាសជាផ្លូវការនូវអនុគណៈកម្មាធិការទាំង ៤* | **លោកស្រី ប៊ុ មល្លិកា**<br>ប្រធានប្រចាំប្រទេសអង្គការ AVI និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិ គ.ស.ក |
| ៩:៣០- ១០:០០ | **វីដេអូខ្លី អំពី**<br>• *លទ្ធផលការងារសំខាន់ៗប្រចាំឆ្នាំ២០១៥របស់ **CCC** និងផែនការសម្រាប់ឆ្នាំ២០១៦*<br>• *បទបង្ហាញអំពីរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៥ និងថវិកា ២០១៦*<br><br>*សំណួរ ចម្លើយ* | **លោកស្រី ស៊ិន ពុទ្ធារី**<br>ប្រធានផ្នែកទំនាក់ទំនង និងការអភិវឌ្ឍសមាជិក គ.ស.ក<br><br>**លោកស្រី *Estelle Roesch***, ហិរញ្ញិក គណៈកម្មាធិការប្រតិបត្តិ គ.ស.ក និងជានាយិកាអង្គការ (E&D) |
| ១០:០០–១០:២០ | ថតរូបរួមគ្នា សម្រាកទទួលទានភេសជ្ជៈ និងទស្សនាពិព័រណ៍ | ទាំងអស់គ្នា |

| ម៉ោង | ប្រធានបទ | អ្នកទទួលខុសត្រូវ |
|---|---|---|
| ១០:២០-១២:០០ | **វគ្គចែកជាក្រុម: ការវាយតម្លៃពាក់កណ្ដាលគម្រោងនៃកម្មវិធី *GHP* និងសកម្មភាព៥ឆ្នាំបន្ទាប់ ស្ថានភាពអង្គការសង្គមស៊ីវិលនៅក្នុងបរិបទ** LANGO **និង** SDGs<br>*បញ្ជាក់: អ្នកចូលរួមនឹងត្រូវបានបែងចែកជាបីក្រុមដូចដែលបានបង្ហាញខាងក្រោមនេះដោយ ផ្អែកលើការចាប់អារម្មណ៍របស់ពួកគេ។ ក្រដាស់ពណ៌ដែលមានលេខក្រុម នឹងត្រូវបានចែកនៅក្នុងពេលចុះឈ្មោះដើម្បីកំណត់អត្តសញ្ញាណក្រុមដែលពួកគេចូលចិត្ត។ ក្រុមនីមួយនឹងត្រូវបានចាប់ផ្ដើមជាមួយនឹងការធ្វើបទបង្ហាញរយៈពេល ៣០ នាទី រួមទាំងការពិភាក្សាដោយមានអ្នកសម្របសម្រួល ក្នុងការធ្វើការសង្ខេបឡើងវិញ ១០ នាទី។ អ្នកកត់ត្រាសម្រាប់ក្រុមនីមួយនឹងត្រូវបានផ្ដល់ជូនទេប៉ុន្តែក្រុមនីមួយៗនឹងត្រូវតែងតាំងអ្នករាយការណ៍ត្រឡប់ពីបេកគំហើញរបស់ពួកគេនៅក្នុងសម័យប្រជុំពេលរសៀល។ ការរាយការណ៍ត្រឡប់នេះនឹងមានរយៈពេល ១០ នាទី។ អ្នកចូលរួមអាចសួរ សំណួរនិងចម្លើយបន្ទាប់ពីក្រុមធ្វើបទបង្ហាញ* | |
| | ១. ពង្រាងការរកឃើញសំខាន់ៗ និងអនុសាសន៍ទៅលើការវាយតម្លៃពាក់កណ្ដាលកម្មវិធី GHP សម្រាប់ឆ្នាំ២០១៤-២០១៨ និងផែនការបន្តរបស់CCC សម្រាប់២០១៦-២០២០<br>*បទបង្ហាញស្ដីពីការរកឃើញនិងអនុសាសន៍លើសេចក្តីព្រាងសម្រាប់ GHP សម្រាប់ប្រាំឆ្នាំបន្ទាប់។ ពិភាកនិងធាតុចូល (សិក្ខាសាលាខ្នាតតូចនិងពេញអង្គ) ពីសមាជិកលើអាទិភាពនិងតួនាទីរបស់ CCC សម្រាប់ប្រាំឆ្នាំបន្ទាប់។* | **អ្នកធ្វើបទបង្ហាញ:**<br>**លោកបណ្ឌិត យឹម ឥមជៀន**<br>**លោកបណ្ឌិត *Edward Maningo*,**<br>ទីប្រឹក្សាឯករាជ្យ<br><br>**អ្នកសម្របសម្រួល:**<br>**លោក ឆាត់ សុភាព**<br>ប្រធានគណៈកម្មាធិការប្រតិបត្តិ គ.ស.ក |
| | ២. ស្ថានភាពអង្គការសង្គមស៊ីវិលក្នុងបរិបទ LANGO<br>*វីដេអូ និងបទបង្ហាញ គ្គីព្រួយបារម្មណ៍ កិច្ចខិតខំប្រឹងប្រែង ) (សង្ខេបនៃករណីសិក្សា និងផែនការបន្ទាប់* | **អ្នកធ្វើបទបង្ហាញ:**<br>**លោកមី ណាក់**<br>ប្រធានសមាសភាពទី ៣ គ.ស.ក<br><br>**អ្នកសម្របសម្រួល:**<br>**លោក ប៉ា ចួនឡៀង**<br>នាយកអង្គការ CCIM |
| | ៣. ស្ថានភាពអង្គការសង្គមស៊ីវិលក្នុងបរិបទ SDGs<br>*ការធ្វើការស្រាវជ្រាវសម្រាប់អង្គការដែលធ្វើការផ្ដោតសំខាន់ទៅលើគោលដៅរបស់ SDGs ដំណើរការ នៃការធ្វើមូលដ្ឋានីយកម្ម SDGs ផែនការបន្ទាប់សម្រាប់អង្គការសង្គមស៊ីវិល និងការពិភាក្សាអំពីយុទ្ធសាស្រ្តក្នុងការធ្វើមូលដ្ឋានី-* | **អ្នកធ្វើបទបង្ហាញ:**<br>**លោកស្រីបណ្ឌិត អែល សុធារី**<br>ប្រធានកម្មវិធី គ.ស.ក |

| ម៉ោង | ប្រធានបទ | អ្នកទទួលខុសត្រូវ |
|---|---|---|
| | *យកម្ម SDGs* | **អ្នកសម្របសម្រួល:**<br>**កញ្ញា ស្រី សុធាវ**<br>អនុប្រធានគណៈកម្មាធិការប្រតិបត្តិ គ.ស.ក |
| ១២:០០-១៣:០០ | អាហារសាមគ្គី និងទស្សនាពិព័រណ៍ | ទាំងអស់គ្នា |
| ១៣:០០-១៤:១៥ | • វីឌីអូពីវឌ្ឍនភាពការងាររបស់ CCC រយៈពេល២៥ឆ្នាំ<br>• ការរាយការត្រឡប់ពី ក្រុម១ ក្រុម២ ក្រុម៣ | |
| ១៤:១៥-១៥:៣០ | **កិច្ចពិភាក្សាពេញអង្គ៖ ការរៀបចំភាពជា ដៃគូសម្រាប់ការធ្វើមូលដ្ឋានីយកម្ម *SDGs***<br>*ផ្តោតលើការប្តេជ្ញាចិត្តរបស់តួអង្គអភិវឌ្ឍន៍ ក្នុងនោះរួមមាន អង្គការសង្គមស៊ីវិល រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើមូលដ្ឋានីយកម្ម **SDGs** ក្នុងបរិបទកម្ពុជា។ កិច្ចពិភាក្សាបន្តមានដូចជា៖*<br>*១. សង្ខេបលទ្ធផលពីក្រុមពិភាក្សាលើយុទ្ធសាស្ត្រអង្គការសង្គមស៊ីវិលលើ SDGs*<br>*២. កិច្ចអន្តរាគមន៍សំខាន់ៗពីអ្នកវាគ្មិន*<br>*៣.ជជែកដេញដោលគ្នារវាងវាគ្មិន និង អ្នកចូលរួម* | **អ្នកសម្របសម្រួល៖**<br>**លោក ម៉ម សម្បត្តិ**<br>នាយកប្រតិបត្តិ ***DPA***<br>**វាគ្មិនពិភាក្សា៖**<br>**លោក សឿង សារឿន**<br>នាយកប្រតិបត្តិ **គ.ស.ក**<br>**លោកស្រី *Claire Van Der Vaeren***<br>អ្នកសម្របសម្រួលប្រចាំប្រទេសរបស់ ***UNCT***<br>**លោកចាន់ វាសនា**<br>ក្រុមប្រឹក្សាភិបាលសមាគមសហគ្រិនវ័យក្មេង និងនាយកគ្រប់គ្រង ***APV*** |
| ១៥:៣០-១៥:៤៥ | អាហារសាមគ្គី និងទស្សនាពិព័រណ៍ | |
| ១៥:៤៥-១៦:៤៥ | **ការព្រមព្រៀងលើតួនាទី សកម្មភាពអាទិភាព និងភាពជាដៃគូរបស់អង្គការ CCC ក្នុងរយៈពេល៥ឆ្នាំទៀត** | **លោក ប៉ា ខួនឡេង**<br>នាយកអង្គការ CCIM និងជាគណៈកម្មាធិការប្រតិបត្តិគ.ស.ក |
| ១៦:៤៥–១៦:៥០ | **ការវាយតម្លៃកិច្ចប្រជុំ** | អ្នកចូលរួមទាំងអស់គ្នា |
| ១៦:៥០–១៧:០០ | **សុន្ទរកថាបិទ** | **កញ្ញា ស្រី សុធាវ**<br>នាយកប្រតិបត្តិ អង្គការ ***ACT***<br>និងជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិ គ.ស.ក |

គ.ស.ក រក្សាសិទ្ធកែប្រែកម្មវិធីក្នុងករណីចាំបាច់